## ការហូរឈាមច្រមុះ

ការហូរឈាមពីច្រមុះ កើតឡើងជាញឹកញាប់បំផុត នៅពេលដែលសរសៃឈាមតូចៗនៅខាងក្នុងរន្ធច្រមុះបានដាច់រហែក ដោយសារខ្យល់បុកទៅច្រមុះខ្លាំង រឺជាលទ្ធផលនៃការកន្ទាស ការឆ្កឹះ រឺ ការញៀសសំបោរ។ ឈាមច្រមុះក៏អាចកើតឡើងពីលទ្ធផលនៃការកើនសំពាធឈាមខ្ពស់។

**គោលបំណងរបស់អ្នក** គឺដើម្បីទប់ស្កាត់ការបាត់បង់ឈាម និង ដើម្បីរក្សាផ្លូវដង្ហើមអោយនៅចំហរ។

**ការព្យាបាល** ដាក់អោយអ្នកជំងឺអង្គុយចុះ។ ផ្អៀងក្បាលអ្នកជំងឺទៅមុខដើម្បីអោយឈាមហូរចេញពីរន្ធច្រមុះ។ សូមអោយអ្នកជំងឺដកដង្ហើមតាមមាត់ (វានឹងមិនមានឥទ្ធិពលប៉ះពាល់ដោយខ្យល់) និង ច្របាច់ផ្នែកទន់នៃច្រមុះ។ សូមនិយាយលើកទឹកចិត្ត និង ជួយអ្នកជំងឺបើចាំបាច់។ ប្រាប់អ្នកជំងឺអោយរក្សាការច្របាច់ច្រមុះនោះ។ ផ្តល់ដំបូន្មានអោយអ្នកជំងឺកុំអោយនិយាយ លេប ក្អក ស្តោះ រឺហឺតខ្យល់ចូល ពីព្រោះវាអាចរំខានដល់កំណកឈាម ដែលអាចនឹងកំពុងកកក្នុងច្រមុះ។ បន្ទាប់ពី១០នាទី ប្រាប់អោយអ្នកជំងឺឈប់ច្របាច់ច្រមុះ។ ប្រសិនបើការហូរឈាមមិនទាន់ឈប់ ប្រាប់គាត់អោយច្របាច់ច្រមុះអោយបាន រយៈពេល ១០នាទីពីរដងទៀត។ នៅពេលឈាមឈប់ហូរដោយអ្នកជំងឺនៅអោនក្បាលទៅមុខ ត្រូវសំអាតជុំវិញច្រមុះដោយប្រើទឹកក្តៅឧណ្ហៗ។ ផ្តល់ដំបូន្មានដល់អ្នកជំងឺអោយសំរាកស្ងៀមចំនួនពីរបីម៉ោង។ ប្រាប់អ្នកជំងឺកុំអោយប្រើកំលាំងខ្លាំង និង ជាពិសេសមិនអោយបញ្ចេញខ្យល់ខ្លាំង តាមច្រមុះ ពីព្រោះសកម្មភាពទាំងនេះធ្វើអោយរំខានដល់កំណកឈាម។

## វត្ថុអ្វីមួយចូលភ្នែក

ជាធម្មតា វត្ថុទាំងនោះអាចលាងយកចេញយ៉ាងស្រួល។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនត្រូវប៉ះអ្វីមួយដែលនៅស្អិតជាប់ទៅនឹងភ្នែក, ដែលចូលទៅក្នុងគ្រាប់ភ្នែក រឺ ដែលស្ថិតនៅលើផ្នែកពណ៌នៃភ្នែកឡើយ (ប្រស្រីភ្នែក និង កូនក្រមុំ) ព្រោះវាអាចធ្វើអោយខូចភ្នែក។ ជំនួសមកវិញ ចូរអោយប្រាកដថាអ្នកជំងឺទទួលបានការថែទាំពីផ្នែកវេជ្ជសាស្ត្រទាន់ពេលវេលា។

**ការព្យាបាល:** គោលបំណងរបស់អ្នក គឺការពារការរងរបួសដល់ភ្នែក។

- ដាក់អោយអ្នកជំងឺអង្គុយបែរមុខទៅពន្លឺ។
- ញែកត្របកភ្នែកទាំងពីរដោយថ្នមៗ ដោយប្រើម្រាមដៃចង្អុល និង មេដៃរបស់អ្នក។
- ត្រូវពិនិត្យគ្រប់ផ្នែកនៃភ្នែក អោយអ្នកជំងឺមើលទៅលើ ក្រោម ឆ្វេង និង ស្តាំ

  *ប្រសិនបើអ្នកឃើញវត្ថុណាមួយនៅផ្នែកសនៃភ្នែក:*
- លាងយកវាចេញដោយប្រើទឹកស្អាតសំរាប់លាងភ្នែក រឺ ទឹកស្អាតចាក់មកពីកែវ។
- ដាក់ក្បាលអ្នកជំងឺទៅកន្លែងរងរបួស ហើយដាក់កន្សែង រឺ ទ្រនាប់ដាក់លើស្មារបស់អ្នកជំងឺ។
- ចាក់ទឹកពីក្តោងច្រមុះអោយវាហូរកាត់ និង បង្ហូរលាងភ្នែក។
- ប្រសិនបើមិនជោគជ័យ យកវត្ថុនោះចេញពីផ្នែកសនៃភ្នែក ដោយប្រើជក់សំឡីសើម។
- ប្រសិនបើវានៅមិនជោគជ័យទៀត ត្រូវរកជំនួយពីផ្នែកវេជ្ជសាស្ត្រ។

## ចត្តុអ្វីមួយនៅក្រោមត្របកភ្នែកលើ

- អោយអ្នកជំងឺទាញត្របកភ្នែកលើចុះក្រោមមកគ្របលើត្របកភ្នែកក្រោម ។
- រោមភ្នែកក្រោម អាចជួយបោសយកវត្ថុនោះចេញបាន ។

**ប្រុងប្រយត្ន័ះ**

- **កុំប៉ះ**អ្វីដែលកំពុងស្អិតជាប់ រឺ កប់នៅក្នុងគ្រាប់ភ្នែក រឺ ប្រស្រីភ្នែក, គឺកុំប៉ះផ្នែកពណ៌នៃភ្នែក ។
- ដាក់ទ្រនាប់គ្របភ្នែក គ្របលើភ្នែក ។
- យក រឺ បញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ។

## រលាកដោយការដុតកំដៅ និង រលាកដោយអគ្គិធាតុរាចផ្កៅ

**ការព្យាបាល**

- ចាប់ផ្ដើមធ្វើអោយត្រជាក់ភ្លាមៗនៃការរលាកនោះ ដោយដាក់វានៅក្រោមទឹកកំពុងហូររយះពេលយ៉ាងតិច១០នាទី
- បន្តចាក់ទឹកត្រជាក់នៅលើកន្លែងរលាកនោះយ៉ាងតិច១០នាទី រឺ រហូតដល់ការឈឺចាប់បានថយចុះ ។
- ដោះគ្រឿងអលង្កា នាឡិកា រឺ សំលៀកបំពាក់ពីកន្លែងដែលរងរបួសនោះ—លុះត្រាវាជាប់ទៅនឹងស្បែក ។
- គ្របកន្លែងរលាកនោះដោយប្រើសំភារៈស្អាត មិនមានជាតិសំឡីរោម ដើម្បីការពារវាកុំអោយមានការបង្ករោគ ។

ប្រសិនបើការរលាកតូចតាចនោះ ធំជាងទំហំតែមប្រៃសណីយ៍ វាត្រូវការ ការយកចិត្តទុកដាក់ពីផ្នែកវេជ្ជសាស្ត្រ ។

គ្រប់ការរលាកជ្រៅទំហំណាក៏ដោយ ត្រូវការអោយមានការព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់ ។

## ការហូរឈាម

**ការដាច់មុតតូចតាច, ការរលាត់, ការប្រេះស្បែក**

**ការព្យាបាល**

- លាង និង សំងួតដៃរបស់អ្នកឯងផ្ទាល់ ។
- គ្របស្នាមដាច់នៅលើដៃរបស់អ្នកផ្ទាល់ ហើយពាក់ស្រោមដៃប្រើហើយបោះចោល ។
- ប្រសិនបើកខ្វក់ លាងសំអាតស្នាមមុតដាច់នោះនៅក្រោមទឹកដែលកំពុងហូរ ។ ជូតសំងួតដោយប្រើក្រណាត់ស្អាត រឺ សំភារៈស្អាតដែលគ្មានកំទេច ។ ប្រសិនបើទៅរួច លើកកន្លែងដែលរងគ្រោះនោះអោយខ្ពស់ជាងបេះដូង ។
- គ្របស្នាមមុតដាច់នោះជាបណ្ដោះអាសន្ន ខណៈពេលអ្នកសំអាតស្បែកដែលនៅជុំវិញជាមួយសាប៊ូនិងទឹក ហើយជូតសំងួតស្បែកដែលនៅជុំវិញនោះ ។ គ្របកន្លែងមុចដាច់នោះអោយបានពេញលេញ ជាមួយក្រណាត់ស្អាត រឺ បង់បិតដំបៅ ។

## ការហូរឈាមធ្ងន់ធ្ងរ

**ការព្យាបាល**

- ពាក់ស្រោមដៃប្រើហើយបោះចោល ។
- សង្កត់របួសនោះដោយប្រើដុំទ្រាប់ (ឧទាហរណ៍ ក្រណាត់ស្អាត) រឺ សង្កត់ដោយម្រាមដៃរហូតដល់រកក្រណាត់ស្អាតប្រើបាន
- លើក និង ទ្រ អវៈយវៈដែលរងរបួសនោះ ។ ត្រូវយកចិត្តទុកដាក់ជាពិសេស ប្រសិនបើអ្នកសង្ស័យថា ឆ្អឹងបានបែកបាក់ ។
- ដាក់អ្នកជំងឺដេកដើម្បីព្យាបាល shock ។
- រុំទ្រនាប់ រឺក្រណាត់នោះអោយជាប់ល្អដើម្បីទប់ស្កាត់ការហូរឈាម ប៉ុន្តែមិនត្រូវតឹងពេកទេ ដែលអាចអោយចរន្តឈាមឈប់ហូរទៅម្រាមដៃ រឺ ម្រាមជើង ។ ប្រសិនបើការហូរឈាមនោះជ្រាបចេញតាមបង់រុំទី១ ត្រូវរុំជាមួយបង់ទី២ទៀត ។ ប្រសិនបើឈាមនៅជ្រាបចេញតាមបង់រុំនោះទៀត ត្រូវយកវាចេញ ហើយរុំម្តងទៀត ។
- ព្យាបាល shock ។
- ទូរសព្ទហៅឡានសង្គ្រោះបន្ទាន់ ។

## វត្ថុអ្វីមួយនៅក្នុងរបួស

ប្រសិនបើអាច ផ្លិត រឺ លាងវត្ថុតូចៗចេញពីរបួសដោយទឹកស្អាត ។ ប្រសិនបើមានវត្ថុធំនៅកប់ខាងក្នុងៈ

**ការព្យាបាល**

- ទុកវានៅនឹងកន្លែង ។
- សង្កត់នៅចំហៀងណាមួយនៃវត្ថុនោះ ។
- លើក និង ទ្រ អវៈយវៈ រឺ ផ្នែកដែលរងរបួស ។
- ដាក់អ្នកជំងឺអោយដេកសំរាក ដើម្បីព្យាបាល shock ។
- គ្របរបួសនិងវត្ថុនោះថ្នមៗ ដោយក្រណាត់ស្អាត ។
- រុំបង្កើតទ្រនាប់ជុំវិញវត្ថុនោះ រហូតដល់ទ្រនាប់នោះខ្ពស់ជាងវត្ថុដែលនៅក្នុងរបួសនោះ បន្ទាប់មករុំបង់លើវត្ថុនោះដោយមិនសង្កត់លើវា ។
- អាស្រ័យលើភាពធ្ងន់ធ្ងរនៃការហូរឈាមនោះ អាចទូរសព្ទហៅឡានពេទ្យ រឺ នាំយកអ្នកជំងឺនោះទៅមន្ទីរពេទ្យ ។